អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

កម្មវិធីសាលារៀនជំនាន់ថ្មី

# ការប្រើប្រាស់ទម្រង់សំណួរសម្រាប់
# បង្កើតតេស្តប្រឡង

## Using Question Formats in Test Development

កំពង់ចាម ២០១៩

# មាតិកា

I. សេចក្តីផ្តើម........................................................................1

II. សំណួរជ្រើសរើស ..................................................................3

III.សំណួរចម្លើយខ្លី ...................................................................8

IV.សំណួរផ្គូរផ្គង........................................................................11

V. សំណួរខុសត្រូវ......................................................................13

VI. សំណួរចំណែកថ្នាក់ ..............................................................14

VII. សំណួរសំណេរ.....................................................................17

# I. សេចក្ដីផ្ដើម

នៅពេលចែកតេស្តប្រឡង យើងមានប្រភេទសំណួរជាមូលដ្ឋានពីរយ៉ាង ដែលអ្នកសរសេរតេស្តត្រូវដឹង។ ប្រភេទសំណួរទាំងពីរនេះគឺ សំណួរមិនលំអៀង និង សំណួរលំអៀង។ ជាទូទៅសំណួរមិនលំអៀងត្រូវបានឆ្លើយយ៉ាងរហ័ស មានចម្លើយត្រឹមត្រូវតែមួយប៉ុណ្ណោះ ហើយសង្កត់ធ្ងន់លើផលចុងក្រោយបង្អស់ក្នុងការសិក្សា (មានន័យថា យើងចង់ដឹងថាសិស្សអាចឆ្លើយនឹងសំណួរ ឬ មិនអាច)។ គេពុំមានកង្វល់អំពីផ្នែកទាំងឡាយនៃលំនាំ(ឧទាហរណ៍របៀបបូកលេខពីតួ) ដែលសិស្សមិនដឹងនោះ ឡើយ។ ជាធម្មតាសំណួរមិនលំអៀងមានការលំបាកបំផុតក្នុងការសរសេរប៉ុន្តែងាយស្រួលក្នុងការកែ។ ឧទាហរណ៍ទូទៅនៃសំណួរមិនលំអៀងរួមមានៈ សំណួរជ្រើសរើស (សំណួរដែលឱ្យចម្លើយច្រើនដើម្បីធ្វើការជ្រើសរើស) សំណួរចម្លើយខ្លី និងសំណួរផ្គូរផ្គង។




ចំណែកឯសំណួរលំអៀងវិញ តែងតែប្រើពេលយូរក្នុងការឆ្លើយ មានចម្លើយច្រើន ដែលកំណែអាចប្រែប្រួល ទៅតាមការបកស្រាយរបស់អ្នកកែ ហើយសង្កត់ធ្ងន់លើលំនាំនៃការសិក្សា។ សំណួរលំអៀងគ្រូមានការងាយស្រួលក្នុងការតែង ប៉ុន្តែមានការលំបាកណាស់ក្នុងការកែ។ រីឯសំណួរសំណេរ (Essay Question) អាចជាឧទាហរណ៍ល្អបំផុត នៃសំណួរលំអៀងវាអាចរួមបញ្ចូលទម្រង់ផ្សេងៗជាច្រើនផងដែរ។ ឧទាហរណ៍ សំណួរដែលបានបង្ហាញខាងក្រោមទាំងពីរនេះ សួរព័ត៌មានដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ ចម្លើយខុសរបស់សិស្សដែលបានបង្ហាញឱ្យឃើញវាផ្តល់ដល់អ្នកកែនូវព័ត៌មានខុសៗគ្នា អំពីការសិក្សារបស់សិស្ស សំណួរពហុជ្រើសរើសគ្រាន់តែបង្ហាញថា សិស្សមិនដឹងពីរបៀបបូកលេខ។ ទោះយ៉ាងណាក៏ដោយ សំណួរដែលផ្តល់ចម្លើយនៅផ្នែកខាងស្តាំ បង្ហាញថាសិស្ស

55+35=

ក. 75

ខ. 80

(គ.) 81

ឃ. 90

55
+35
810

នៅមិនទាន់យល់ពីរបៀបត្រាទុក នៅពេលធ្វើលេខបូក។ នេះហើយគឺវាបង្ហាញកំហុសនៅក្នុង " លំនាំ " នៃការបូកលេខ។

ព័ត៌មាននេះមានសារៈប្រយោជន៍ចំពោះគ្រូ ដើម្បីដឹងក្នុងការរំឭកខ្លឹមសារមេរៀនឬជួយសិស្សជាបុគ្គល។ ដូច្នេះ វាមានសារៈប្រយោជន៍ណាស់ចំពោះប្រភេទនៃការវាយតម្លៃបែបដំណាក់ (Formative)។ នៅក្នុងសៀវភៅណែនាំនេះ យើងនឹងពិភាក្សាពីទម្រង់សំណួរ ៦ យ៉ាង។ ទម្រង់សំណួរទាំងនោះរួមមានៈ សំណួរជ្រើសរើស សំណួរចម្លើយខ្លី សំណួរផ្គូរផ្គង សំណួរខុសត្រូវ សំណួរចំណាត់ថ្នាក់ និងសំណួរសំណេរ។

# II. សំណួរជ្រើសរើស

## A. ព័ត៌មានទូទៅ: គុណសម្បត្តិ និង គុណវិបត្តិ

- សំណួរជ្រើសរើស គឺជាទម្រង់សំណួរ មិនលំអៀងដែលមានភាពទន់ភ្លន់បត់បែនជាងគេបំផុត។ វាអាចត្រូវ បានប្រើដើម្បីធ្វើតេស្តបំណិននៃការគិត ដែលបានពីការចងចាំ ធ្វើ តេស្តលើការយល់ដឹង ការអនុវត្ត និង ការវិភាគ។
- សំណួរជ្រើសរើស មានកម្រិតខ្ពស់ជាង សំណួរ ត្រូវ-ខុស ពីព្រោះទម្រង់ចម្លើយដ៏ច្រើនរបស់វា ជួយកាត់បន្ថយភាពប៉ាន់ស្មានទៅលើចម្លើយត្រឹមត្រូវ។
- គុណសម្បត្តិសំខាន់ជាងគេមួយទៀត របស់សំណួរជ្រើសរើស គឺវាផ្តល់លទ្ធភាពឱ្យការបូកសរុបលើបំណិននៃការសរសេរ។ គុណសម្បត្តិនេះបង្កើនយ៉ាងខ្លាំងក្លានូវសុពលភាពនៃតេស្ត។
- គុណវិបត្តិទាំងឡាយជាចម្បងនៃសំណួរជ្រើសរើស គឺថាវាមានការលំបាកបំផុតក្នុង ការសរសេរ តម្រូវលក្ខខណ្ឌតេស្តតឹងរឹង ដើម្បីបង្ការការចម្លងគ្នា ហើយវាអាចនឹងនៅមានកម្រិតខ្លះនៃការប៉ាន់ស្មានក្នុងការរកចម្លើយដែលត្រឹមត្រូវ។

## B. ទម្រង់ជាមូលដ្ឋាននៃសំណួរជ្រើសរើស

1. ផ្នែកមែកធាង (The Stem)

- ផ្នែកមែកធាងនៃសំណួរជ្រើសរើស តែងតែត្រូវបានប្រើពាក្យ ដែលជាសំណួរផ្ទាល់តែម្តង ឬជាល្បះមិនពេញលេញ។

  ឧទាហរណ៍: នៅប្រទេសកម្ពុជា តើខេត្តណាដែលមានប្រជាជនច្រើនជាងគេ?

  ក. បាត់ដំបង

  ខ. តាកែវ

  គ. កំពង់ចាម

  ឃ. កណ្តាល

  ខេត្តដែលមានប្រជាជនច្រើនជាងគេនៅប្រទេសកម្ពុជាគឺ:

  ក. បាត់ដំបង ។

  ខ. តាកែវ ។

  គ. កំពង់ចាម ។

  ឃ. កណ្តាល ។

- កត់សម្គាល់ក្នុងឧទាហរណ៍ ខាងលើថា ចម្លើយទាំងឡាយដែលជាល្បះពេញលេញត្រូវដាក់សញ្ញា (។) នៅចុងបញ្ចប់ល្បះនីមួយៗ។ ផ្នែកមែកធាងដែលជាសំណួរពេញលេញ ដូចជានៅក្នុងឧទាហរណ៍ទី ១ ត្រូវដាក់សញ្ញាសួរ ( ? )។

2. ផ្នែកចម្លើយ

- សំណួរជ្រើសរើស តែងតែមានចម្លើយដែលអាចឆ្លើយបាន ៤ ឬ ៥ ហើយក្នុងបណ្ដាចម្លើយទាំងនោះ គឺមានចម្លើយតែមួយប៉ុណ្ណោះដែលត្រឹមត្រូវ។ ចម្លើយដែលអាចឆ្លើយបានតិចជាង ៤ មិនបានណែនាំឱ្យប្រើទេ ព្រោះបង្កើតលទ្ធភាពឱ្យឆ្លើយបានត្រឹមត្រូវទៅតាមការស្មាន (មានន័យថា វាអាចប៉ះពាល់លើភាពជឿទុកចិត្តនៃសំណួរ (Reliability)។
- ចម្លើយអាចត្រូវបានបង្ហាញដោយអក្សរ ឬ លេខ ។ ចម្លើយគួរតែត្រូវបានរៀបចំក្នុងលំដាប់សមស្របទៅតាមពេលវេលារបស់វា។ ឧទាហរណ៍

| **<u>មិនល្អ</u>** | **<u>ល្អ</u>** |
|---|---|
| ប្រទេសកម្ពុជាបានក្លាយជាប្រទេសឯករាជ្យពីប្រទេសបារាំងក្នុងឆ្នាំ | ប្រទេសកម្ពុជាបានក្លាយជាប្រទេសឯករាជ្យពីប្រទេសបារាំងក្នុងឆ្នាំ |
| ក. 1960 ។ | ក. 1948 ។ |
| ខ. 1954 ។ | ខ. 1954 ។ |
| គ. 1975 ។ | គ. 1960 ។ |
| ឃ. 1948 ។ | ឃ. 1975 ។ |

- ក្នុងករណីភាគច្រើនត្រូវបានណែនាំឱ្យរៀបចម្លើយបញ្ឈរជំនួសការរៀបផ្ដេក។ តែទោះជាយ៉ាងណាការរៀបចំចម្លើយផ្ដេកអាចត្រូវបានប្រើ បើចម្លើយទាំងនោះខ្លី។

| <u>ការរៀបបញ្ឈរ</u> | <u>ការរៀបផ្ដេក</u> |
|---|---|
| តើក្រុមលេខណាមួយខាងក្រោមនេះ ដែលរៀបតាមលំដាប់ពីធំជាងគេបង្អស់មកតូចជាងគេបង្អស់បានត្រឹមត្រូវ? | ចូរកំណត់ថ្នាក់ពាក្យ "ទាសករ" ក.នាម,ខ.គុណនាម, គ. កិរិយាស័ព្ទ , ឃ.សព្វនាម |
| ក. 663540 . 5334333 . 744236. 537062 | |
| ខ. 32294 . 136428 . 475536 . 210697 | |
| គ. 6105675 . 3676037 . 332106 . 335045 | |
| ឃ. 864954 . 496862 . 357152 . 186243 | |

## C. ប្រភេទខុសគ្នានៃសំណួរជ្រើសរើស

- សំណួរជ្រើសរើសមាន ៤ ជាមូលដ្ឋាន។ ប្រភេទទាំងនោះគឺប្រភេទចម្លើយត្រូវ ប្រភេទចម្លើយល្អបំផុត ប្រភេទចម្លើយអវិជ្ជមាន និង ប្រភេទចម្លើយច្រើន។ ប្រភេទនីមួយៗត្រូវបានពន្យល់ដូចខាងក្រោម៖

1. **ប្រភេទចម្លើយត្រូវ:**

- នៅក្នុងសំណួរបែបនេះ ចម្លើយតែមួយគត់ដែលត្រឹមត្រូវពេញលេញ។ ចម្លើយដទៃទៀតខុសទាំងស្រុង។

ឧទាហរណ៍: ម្តាយខ្ញុំមានប្រាក់ 5000៛ ទៅផ្សារ។ គាត់ទិញត្រីអស់ 800៛ សាច់ជ្រូក 2400 ៛។ តើគាត់នៅសល់ប្រាក់ប៉ុន្មាន?

ក. 1500៛

ខ. 1800៛

គ. 1850៛

ឃ. 1870៛

2. ប្រភេទចម្លើយល្អបំផុត

- ក្នុងសំណួរបែបនេះ ចម្លើយនីមួយៗមានជាតុខ្លះពិត។ សិស្សត្រូវជ្រើសរើសយកចម្លើយណាដែលត្រឹមត្រូវជាងគេបំផុត។

  ឧទាហរណ៍: តួចែកនៃ 12 មាន:

  ក. 1.2.3.4.6.12

  ខ. 1.3.4.6.8.12

  គ. 1.2.4.5.6.12

  ឃ. 1.2.4.6.8.12

- ក្នុងឧទាហរណ៍ នេះមានជាតុខ្លះពិតនៅក្នុងចម្លើយនីមួយៗ។ ឧទាហរណ៍ក្នុងចម្លើយ ខ លេខ 3.4.12 អាចជាតួចែកនៃ 12 ប៉ុន្តែ 8 មិនអាចជាតួចែកនៃ 12 ទេ។ ទោះជាយ៉ាងណាក៏ដោយមានចម្លើយ ក ប៉ុណ្ណោះ ដែលជាចម្លើយត្រឹមត្រូវពេញលេញ។

## 3. ប្រភេទចម្លើយអវិជ្ជមាន

- ក្នុងសំណួរបែបនេះ សិស្សត្រូវជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

  ឧទាហរណ៍: ល្បះទាំងអស់បញ្ជាក់ពីលក្ខណៈរបស់ពោត លើកលែងតែ៖

  ក. ពោតជាដំណាំប្រចាំរដូវ។

  ខ. ពោតជាដំណាំធញ្ញជាតិ។

  គ. ផ្កាញី និង ឈ្មោលនៅជាមួយគ្នា។

  ឃ. គេយកម្សៅពោតធ្វើនំ។

## 4. ប្រភេទចម្លើយច្រើន៖

- ក្នុងសំណួរបែបនេះកិច្ចការរបស់សិស្សគឺត្រូវជ្រើសរើសនូវ ចម្លើយដែលត្រូវជ្រើសរើសយកមួយ ឬផ្សំចម្លើយដែលត្រូវជ្រើសរើសយក ដែលជាចម្លើយត្រឹមត្រូវ។

  ឧទាហរណ៍:







| (I) | (II) | (III) | (IV) | (V) |
|---|---|---|---|---|

រូបណាខ្លះខាងលើនេះ ដែលបង្ហាញពីពួកសត្វគ្មានឆ្អឹងកង?

ក. I គត់

ខ. II, III និង IV

គ. II, IV និង V

ឃ. I, III និង V

D. ***សំណួមពរនៅពេលសរសេរសំណួរជ្រើសរើស***

- គោលការណ៍ណែនាំដូចតទៅនេះ គួរតែត្រូវបានសង្កេតនៅពេលសរសេរសំណួរជ្រើសរើស:

1. ធ្វើឱ្យប្រាកដថាសំណួរទម្រង់មែកជាងនីមួយៗមានបញ្ហាកំណត់ច្បាស់លាស់។

**ឧទាហរណ៍:**

| <u>**មិនល្អ**</u> | <u>**ល្អ**</u> |
|---|---|
| ភ្នំពេញ | តើភ្នំពេញមានទីតាំងស្ថិតនៅឯណា? |
| ក. មានទីតាំងស្ថិតនៅចតុមុខ។ | ក. នៅកន្លែងមួយហៅថាចតុមុខ |
| ខ. មានទីតាំងស្ថិតនៅខេត្តកណ្ដាល ។ | ខ. ក្នុងខេត្តកណ្ដាល |
| គ. មានទីតាំងស្ថិតនៅខេត្តសៀមរាប ។ | គ. ក្នុងខេត្តសៀមរាប |
| ឃ. មានទីតាំងនៅបឹងទន្លេសាប ។ | ឃ. នៅបឹងទន្លេសាប |

2. កុំប្រើពាក្យច្រើនហួសការចាំបាច់ ក្នុងការធ្វើឱ្យមានអត្ថន័យច្បាស់លាស់។

**ឧទាហរណ៍:**

| <u>**មិនល្អ**</u> | <u>**ល្អ**</u> |
|---|---|
| រុក្ខជាតិពុលគេច្រើនឃើញមាន: | រុក្ខជាតិពុលគេច្រើនឃើញមាននៅក្នុង: |
| ក. នៅក្នុងភូមិ ។ | ក. ភូមិ ។ |
| ខ. នៅក្នុងចម្ការ ។ | ខ. ចម្ការ ។ |
| គ. នៅក្នុងព្រៃ ។ | គ. ព្រៃ ។ |
| ឃ. នៅក្នុងសួនបន្លែ | ឃ. សួនបន្លែ ។ |

3. ធ្វើឱ្យប្រាកដថា ចម្លើយរបស់អ្នកស្របទៅនឹងរចនាសម្ព័ន្ធវេយ្យាករណ៍ ហើយការប្រើពាក្យរបស់អ្នកសម្របទៅនឹងមែកជាង។

**ឧទាហរណ៍:**

**មិនល្អ**

សារៈប្រយោជន៍នៃដើមត្នោតដែល
សំខាន់ជាងគេមានៈ

ក. សម្រាប់យកធ្វើជាអាហារ ។

ខ. ដើម្បីយកទឹក ។

គ. ធ្វើជាព្រំរបង ។

ឃ. ធ្វើទូក ។

**ល្អ**

សារៈប្រយោជន៍នៃដើមត្នោតដែល
សំខាន់ជាងគេគឺៈ

ក. យកធ្វើជាអាហារ ។

ខ. យកទឹក ។

គ. ធ្វើជាព្រំរបង ។

ឃ. ធ្វើទូក ។

4. កុំធ្វើឱ្យចម្លើយរបស់អ្នកជាន់លើគ្នា បានន័យថាចម្លើយមួយមានចម្លើយដទៃទៀតនៅក្នុងនោះ។

**ឧទាហរណ៍ៈ**

មេអំបៅជាសមាជិកនៃក្រុមសត្វណា?

ក. សត្វឥតឆ្អឹងកង ។

ខ. សត្វដែលមានកោសិកាតែមួយ ។

គ. សត្វល្អិត ។

ឃ. សត្វស្លាប ។

5. ព្យាយាមទុកចម្លើយទាំងអស់ក្នុងប្រវែងដូចគ្នា។ ជាញឹកញាប់គ្រូតែងមានទម្លាប់បង្កើតចម្លើយវែងជាងគេបំផុតជាចម្លើយត្រឹមត្រូវ។ បើសិស្សដឹងចំណុចនេះ នឹងអាចជួយពួកគេឱ្យស្មានរកចម្លើយត្រឹមត្រូវដោយគេពុំចេះ។
6. ផ្លាស់ប្តូរទីតាំងចម្លើយត្រូវ និងធ្វើការរំលែកចម្លើយទាំងនោះឱ្យបានស្មើគ្នា។
7. កុំធ្វើឱ្យសំណួរទម្រង់មែកជាងផ្តល់នូវសញ្ញាបង្ហាញ (Clue) ដែលទាក់ទងទៅនឹងចម្លើយត្រឹមត្រូវ។ បញ្ហានេះធ្វើឱ្យខូចសុពលភាពនៃសំណួរ ព្រោះសិស្សអាចស្មានចម្លើយត្រឹមត្រូវដោយគេពុំចេះ។

**ឧទាហរណ៍ៈ**

តើមូលហេតុខាងក្រោមណាខ្លះ អាចបង្កើតឱ្យមានជំងឺ AIDS?

ក. ការញុំាបាយនៅក្នុងហាង ។

ខ. ការរួមភេទ និង ការទទួលឈាម ។

គ. ការប៉ះពាល់គេ ។

ឃ. ការប្រើប្រាស់បង្គន់រួម ។

នៅក្នុងឧទាហរណ៍ខាងលើ ការសួររកកត្តាណា "ខ្លះ" ដែលបង្កើតឱ្យមានជំងឺ AIDS បង្ហាញថាកត្តាដែលមានចម្លើយច្រើនជាងមួយជាចម្លើយត្រឹមត្រូវ។ ដូច្នេះសំណួរទម្រង់មែកជាងដែលមានពាក្យបន្លយអាចនាំសិស្សស្មានថាជាចម្លើយ **ខ** ។

៨. នៅពេលសរសេរសំណួរជ្រើសរើសបែបអវិជ្ជមាន ធ្វើឱ្យលេចធ្លោរឡើងនូវពាក្យអវិជ្ជមាន ដោយគូសបន្ទាត់ពីក្រោមវា ដើម្បីឱ្យសិស្សដឹង ហើយគេត្រូវជ្រើសរើសចម្លើយអវិជ្ជមាន។

**ឧទាហរណ៍:**

ឃ្លាខាងក្រោមនេះពិតទាំងអស់ លើកលែងតែ:

ក. ស្រូវជារុក្ខជាតិស្មៅ ។

ខ. ដើមស្រូវជាដើមតាន់ណែន។

គ. ស្រូវដុះជាគុម្ព ។

ឃ. ស្លឹកស្រូវជាស្លឹកទោល។

# III. សំណួរចម្លើយខ្លី

## A. *ព័ត៌មានទូទៅ*

- សំណួរចម្លើយខ្លីត្រូវបានប្រើក្នុងគោលដៅធ្វើតេស្តលើកម្រិតចងចាំតែប៉ុណ្ណោះ។
- វាក៏មានប្រយោជន៍ផងដែរ នៅពេលដែលគ្រូចង់ធ្វើតេស្តទាមទារសិស្សចងចាំដោយខ្លួនឯង (Recall)។

## A. ប្រភេទខុសៗគ្នានៃសំណួរចម្លើយខ្លី

- មានសំណួរចម្លើយខ្លី បីប្រភេទជាមូលដ្ឋាន។ ប្រភេទទាំងនេះមានដូចតទៅ:

1. **ប្រភេទសំណួរ**

   **ឧទាហរណ៍:**

   តើមានខេត្តប៉ុន្មាននៅប្រទេសកម្ពុជា ?__________

2. ប្រភេទបំពេញ

   **ឧទាហរណ៍:**

   នៅក្នុងភូមិវិទ្យា ទីតាំងខាងជើង ខាងត្បូង និង ខាងលិចនៅលើផែនដីត្រូវបានបង្ហាញដោយប្រើខ្សែរយៈបន្ទាត់ ___________និង__________។

3. ប្រភេទទំនាក់ទំនង

   **ឧទាហរណ៍:**

   ការណែនាំ: នៅក្នុងចន្លោះចំហរដែលត្រូវបំពេញ ចូរសរសេរលេខរ៉ូម៉ាំង ដែលទាក់ទងនឹងលេខខ្មែរដែលផ្តល់ឱ្យ:

   1. ២៣ _____
   2. ១១ _____
   3. ៩ _____

## B. *សំណូមពរនៅពេលសរសេរសំណួរចម្លើយខ្លី:*

1. ធ្វើឱ្យប្រាកដថា សំណួរអាចឆ្លើយបានតែមួយពាក្យ មួយឃ្លាឬលេខត្រឹមតែមួយគត់។

   **ឧទាហរណ៍:**

   **<u>មិនល្អ</u>**

   សភាតំណាងរាស្រ្តនៃប្រទេសកម្ពុជាមកប្រជុំគ្នានៅក្នុង_________។

   បីឬបួនចម្លើយអាចត្រូវបានប្រើក្នុងការឆ្លើយយ៉ាងត្រឹមត្រូវទៅនឹងសំណួរនេះរួមមាន: ភ្នំពេញ មករា និង គ្រោះអាសន្ន។ ដូច្នេះហើយសំណួរនៅក្នុងទម្រង់នេះគឺ អាចមានភាពលំអៀងនៃកំណៃ។ យកល្អសំណួរនេះគួរប្រើពាក្យដូចតទៅ:

   **<u>ល្អ</u>**

   សភាតំណាងរាស្រ្តនៃប្រទេសកម្ពុជាមកប្រជុំនៅទីក្រុង__________។

2. ផ្តល់ចំនួនចន្លោះចំហ ឱ្យស្មើនឹងចម្លើយ។

**ឧទាហរណ៍:**

ឥណ្ឌូចិនបារាំង ត្រូវបានបង្កើតឡើងដោយប្រទេស______ ________និង ________។

3. កុំលុបពាក្យច្រើនពេកពីសំណួរបំពេញ។

**ឧទាហរណ៍:**

_______ចាស់នៃប្រទេសកម្ពុជាគឺ________។

# IV.សំណួរផ្គូរផ្គង

## A. ព័ត៌មានទូទៅ:

- សំណួរផ្គូរផ្គង គឺជាការប្រែប្រួលនៃសំណួរជ្រើសរើស។ វាមានមែកជាងខ្លីៗដែលត្រូវផ្គូរជាមួយចម្លើយមួយចំនួន។

  **ឧទាហរណ៍:**

  ការណែនាំៈ ជ្រើសរើសឈ្មោះខេត្តនៅខាងស្តាំដៃ ដែលទាក់ទងទៅនឹងអាគារល្បីល្បាញនៅខាងឆ្វេង។ សរសេរអក្សរឈ្មោះខេត្តនៅក្នុងចន្លោះចំហនៅខាងស្តាំលេខ។ ឈ្មោះខេត្តអាចត្រូវបានប្រើច្រើនជាងម្តង ឬមិនមានទាល់តែសោះ។

| | |
|---|---|
| 1___អង្គរវត្ត | ក. កំពង់ចាម |
| 2___បាយ័ន | ខ. តាកែវ |
| 3___វិមានឯករាជ្យ | គ. សៀមរាប |
| 4___វត្តភ្នំ | ឃ.ភ្នំពេញ |
| 5___ប្រាសាទទន្លេបាទី | ង. រតនគិរី |
| | ច. បាត់ដំបង |

- គុណសម្បត្តិសំខាន់ជាងគេមួយក្នុងបណ្តាគុណសម្បត្តិសំខាន់ទាំងឡាយ គឺភាពផ្តល់ប្រសិទ្ធភាពរបស់វា។ បានន័យថាមើលលំហាត់ខាងលើនេះ ត្រូវបានសរសេរជាសំណួរជ្រើសរើស នោះវានឹងត្រូវប្រើចន្លោះចំហច្រើនថែមទៀត។
- សំណួរផ្គូរផ្គងតែងតែត្រូវបានប្រើ ដើម្បីវាស់បំណិននៃការគិតលើកម្រិតចងចាំ ក៏ប៉ុន្តែវាអាចវាស់បំណិននៃសំណួរយល់ដឹងផងដែរ។

## B. សំណូមពរនៅពេលសរសេរសំណួរផ្គូរផ្គង:

- នៅពេលសរសេរសំណួរផ្គូរផ្គង ត្រូវសរសេរតាមគោលការណ៍ ណែនាំដូចខាងក្រោមៈ

1. សរសេរការណែនាំឱ្យបានច្បាស់លាស់សម្រាប់លំហាត់ កុំគ្រាន់តែនិយាយថា "ផ្គូរផ្គងចំណុចដូចតទៅ"។ បញ្ជាក់ឱ្យច្បាស់លាស់ក្នុងការបង្ហាញថាត្រូវផ្គូរ ចំណុចទាំងនោះដោយរបៀបណានៅក្នុងការណែនាំដែលផ្តល់ឱ្យ (ឧទាហរណ៍ៈ ការគូសបន្ទាត់ ការសរសេរចម្លើយជាអក្សរនៅក្នុងចន្លោះចំហដែលគេទុកឱ្យបំពេញ ។ល។)។
2. ជានិច្ចកាលមែកជាងនៃសំណួរត្រូវវែង ហើយចម្លើយដែលត្រូវផ្គូរផ្ទឹមត្រូវខ្លី។
3. ប្រើបញ្ជីចំណុចដែលត្រូវឱ្យផ្គូរផ្គងជាបញ្ជីខ្លី។ កុំឱ្យបញ្ជីនោះលើសពី 10 ចំណុច។
4. ប្រើចម្លើយឱ្យបានច្រើនជាងមែកជាងដែលផ្គូរផ្ទឹម។ ធ្វើយ៉ាងនេះនឹងជួយកាត់បន្ថយបំណិនរបស់សិស្សក្នុងការស្មានចម្លើយត្រឹមត្រូវដោយពុំចេះ។
5. រៀបចំចម្លើយទៅតាមលំដាប់ដោយសមហេតុផល បើសិនជាចម្លើយនោះមានលំដាប់របស់វា។

ឧទាហរណ៍: បញ្ជីឆ្នាំរៀបតាមលំដាប់លំដោយតាមឆ្នាំ បញ្ជីចំនួន ឬលេខ រៀបតាមលំដាប់លេខ។ល។

6. ប្រើចម្លើយដែលប្រហាក់ប្រហែលគ្នា។ កុំលាយចម្លើយដែលតាងឱ្យក្រុមខុសៗគ្នានៃអ្វីដែលបានរៀន។ ឧទាហរណ៍: កុំលាយបញ្ចូលគ្នានូវក្រុមដូចជា ក្រុមទន្លេ ក្រុមមនុស្ស និងក្រុមឆ្នាំនៅក្នុងសំណួរតែមួយ។ ខាងក្រោមនេះជា ឧទាហរណ៍ នៃសំណួរផ្គូរផ្គងដែលមិនសមរម្យ

| | |
|---|---|
| 1.____ ស្តេចដែលសង់ប្រាសាទបាយ័ន | ក. កំពង់ចាម |
| 2.____ ខេត្តដែលមានប្រជាជនច្រើនជាងគេបំផុត | ខ. ជ័យវរ្ម័នទី7 |
| 3.____ វិមានឯករាជ្យ | គ. 1954 |
| 4.____ ឆ្នាំឯករាជ្យរបស់ប្រទេសកម្ពុជា | ឃ. ភ្នំពេញ |
| 5.____ប្រាសាទដែលល្បីល្បាញជាងគេនៅកម្ពុជា | ង. រតនគិរី |
| | ច. អង្គរវត្ត |

7. កុំតែងសំណួរផ្គូរផ្គងឱ្យរំលងពីទំព័រមួយទៅទំព័រមួយទៀត៕

## V.សំណួរត្រូវ/ខុស

### A. ព័ត៌មានទូទៅ:

- សំណួរត្រូវ/ខុស ភាគច្រើនជាអំណះអំណាងដែលសិស្សត្រូវសម្រេចថា ត្រូវ ឬ ខុស។
- សំណួរត្រូវ/ខុស មានការលំបាកក្នុងការតែង ពីព្រោះវាលំបាកក្នុងការរកឱ្យឃើញនូវអំណះអំណាងដែលថា ប្រាកដជាខុសដាច់ខាត ឬ ត្រូវដាច់ខាត។ ជួនកាលសូម្បីអ្នកជំនាញក៏ដោយ ក៏នៅតែមិនយល់ស្របថា អំណះអំណាងណាមួយដែលត្រូវ ឬ ខុសនោះទេ។
- ជាទូទៅគ្រូភាគច្រើនយល់ថា សំណួរត្រូវ/ខុសមានការងាយស្រួលណាស់ក្នុងការតែង ប៉ុន្តែពុំមែនដូច្នោះទេ។
- សំណួរត្រូវ/ខុសអាចមានប្រយោជន៍ណាស់ ក្នុងការវាស់ប្រភេទបំណិនចងចាំទៅកម្រិតវាយតម្លៃ។ នេះគឺជាគុណសម្បត្តិដ៏ធំបំផុតមួយក្នុងបណ្តាគុណសម្បត្តិធំៗជាច្រើនទៀតរបស់វា។
- តេស្តប្រឡងបែបបូកសរុបដ៏សំខាន់ៗ យើងមិនគួរប្រើសំណួរត្រូវ/ខុសពីព្រោះសំណួរបែបនេះធ្វើឱ្យសិស្សមានលទ្ធភាពប៉ាន់ស្មានកម្រិតខ្ពស់។

### B. ប្រភេទខុសគ្នានៃសំណួរត្រូវ/ខុស

- មានសំណួរត្រូវ/ខុស 4 ប្រភេទខុសគ្នា ដែលគ្រូអាចប្រើក្នុងការធ្វើតេស្ត។ ប្រភេទទាំងនោះមានដូចតទៅៈ

1. **សំណួរប្រភេទមូលដ្ឋាន (ប្រើប្រាស់ញឹកញាប់)**

- នេះជាប្រភេទសំណួរត្រូវ/ខុសដែលភាគច្រើន គេប្រើទៅលើតេស្ត។ ក្នុងសំណួរបែបនេះគេផ្តល់ឱ្យសិស្សនូវអំណះអំណាងមួយ ហើយឱ្យកំណត់ថា តើវាត្រូវឬខុស។ បើអំណះអំណាងនេះត្រូវសិស្សគូសរង្វង់ "ត"។ បើវាខុស សិស្សត្រូវគូសរង្វង់ "ខ"។

  **ឧទាហរណ៍**

  ត/ខ ចំនួនមួយអាចចែកដាច់នឹង "0"។

  ត/ខ ខ្យល់មានទម្ងន់។

  ត/ខ ជ័យវរ្ម័នទី ៧ ជាស្តេចសម័យអង្គរ។

2. **ប្រភេទកំណែ**

- ក្នុងសំណួរត្រូវ/ខុស បែបនេះសិស្សមិនមែនគ្រាន់តែកំណត់ថា តើអំណះអំណាងនេះត្រូវឬខុសប៉ុណ្ណោះទេ តែក៏ត្រូវកែអំណះអំណាងផងដែរ បើមានការចាំបាច់។

  **ឧទាហរណ៍**

  **ត/ខ** <u>ជ័យវរ្ម័នទី7</u> ជាស្តេចដែលបានសង់ប្រាសាទអង្គរវត្ត។

  ________________________________

- បើសិស្សសម្រេចចិត្តថាអំណះអំណាងខាងលើនេះខុស គេត្រូវមើលទៅឈ្មោះ ដែលមានគូសបន្ទាត់ពីក្រោម ហើយសរសេរឈ្មោះស្តេច ដែលជាក់ស្តែងបានសង់ប្រាសាទអង្គរវត្តនៅ

ក្នុងកន្លែងចំហ ដែលបានទុកឱ្យបំពេញ។ នៅពេលតែងសំណួរបែបនេះគ្រូត្រូវបញ្ជាក់ឱ្យច្បាស់ថាផ្នែកនៅក្នុងអំណះអំណាងដែលតម្រូវឱ្យកែ គឺមានគូសបន្ទាត់ពីក្រោម។

- សំណួរបែបនេះឱ្យគ្រូមានការប្រយត្នប្រយែងក្នុងការកែ ព្រោះថាមាន 2 ចំណុច ដែលឱ្យសិស្សធ្វើ

  1/ បង្ហាញថាតើអំណះអំណាងនោះត្រូវឬខុស និង 2/ កែអំណះអំណាងបើការចាំបាច់។ បើអំណះអំណាងនេះមិនតម្រូវឱ្យកែទេ នោះសិស្សត្រូវទទួលបានពិន្ទុ ចំពោះចម្លើយត្រឹមត្រូវ។ បើអំណះអំណាងនោះខុស ហើយសិស្សបង្ហាញចំណុចនេះដោយត្រឹមត្រូវ តែមិនអាចកែអំណះអំណាងនោះបាន នោះគេទទួលបានពិន្ទុសូន្យ។

3. **ប្រភេទធំជាង/តូចជាង:**

- សំណួរបែបនេះអាចមានប្រយោជន៍ក្នុងគណិតវិទ្យា។ ក្នុងសំណួរបែបនេះសិស្សត្រូវបង្ហាញថាតើចំនួនមួយធំជាងចំនួនមួយទៀតឬទេ? ក្នុងការណែនាំអ្នកតែងតេស្តត្រូវបង្ហាញចំនួនដែលត្រូវប្រៀបធៀបដោយគូសបន្ទាត់ពីក្រោមចំនួននោះ បន្ទាប់មកសិស្សត្រូវបង្ហាញថា តើចំនួននោះធំជាង ឬតូចជាងចំនួនដទៃទៀត។

  **ឧទាហរណ៍**

  ធំជាង / តូចជាង /-70/ +50

4. **ប្រភេទពិត/មតិ**

- សំណួរបែបនេះមានប្រយោជន៍ណាស់ ក្នុងការជួយសិស្សឱ្យចំណាំភាពខុសគ្នារវាងហេតុការណ៍ពិតនិងមតិទស្សនៈ។ ការឆ្លើយនឹងសំណួរបែបនេះត្រូវការបំណិននៃការគិតដល់កម្រិតវាយតម្លៃនៃតាក់សូណូមីប្លូម (Bloom's Taxonomy) ។ សំណួរបែបនេះមានប្រយោជន៍ណាស់ក្នុងការបំប៉នសិស្សឱ្យមានសតិប្រាជ្ញាទូលំទូលាយ មានអ្វីៗដែលត្រូវការជាមុនសម្រាប់សង្គមប្រជាធិបតេយ្យ។ សូមព្យាយាមមើលនូវសំណួរខ្លះខាងក្រោមនេះ ហើយកំណត់ដោយខ្លួនឯងថា តើអំណះអំណាងទាំងនោះជាហេតុការណ៍ពិត ឬ គ្រាន់តែជាមតិយោបល់របស់នរណាម្នាក់។

  **ឧទាហរណ៍:**

  ព/ មតិ សម័យអង្គរ គឺជាសម័យដ៏រុងរឿងបំផុតនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

  ព/ មតិ ប្រជាជនតិចតួចនៅប្រទេសកម្ពុជាចេះនិយាយភាសាអង់គ្លេស។

  ព/ មតិ គណិតវិទ្យា និង ភាសាខ្មែរ សំខាន់ស្មើគ្នា ក្នុងការសិក្សា។

## C. *សំណូមពរនៅពេលសរសេរសំណួរត្រូវ / ខុស*

1. កុំសរសេរអំណះអំណាងវែងពេកព្រោះថា ជាកត្តាមិនទាក់ទងលើការវាស់បំណិនក្នុងការអានជាមួយការឆ្លើយសំណួរបានត្រឹមត្រូវនោះទេ។ សូមចាំថា គោលបំណងនៃសំណួរនេះគឺធ្វើតេស្តអំពីការយល់ដឹងរបស់សិស្សទៅលើគោលដៅសិក្សាជាក់លាក់ តែពុំមែនជាបំណិនរបស់ពួកគេក្នុងការអាននោះទេ។

2. នៅពេលសរសេរសំណួរត្រូវ / ខុស ចៀសវាងពាក្យដូចជាៈ ជាដរាប មិនដែល ទាំងអស់ គ្មានទាល់តែសោះ។ សិស្សអាចដឹងថាពាក្យទាំងនេះជាការកំណត់ចម្លើយចំៗ និង ជាការផ្តល់សញ្ញាបង្ហាញរួចទៅហើយ ដូចជាថាតើអំណះអំណាងមួយត្រូវ ឬខុសនោះ ត្រូវបានវិនិច្ឆ័យតាមចំណុចខ្លះថា <u>ពិតជាដរាបឬមិនដែលពិតទាល់តែសោះ រួ</u>ចទៅហើយ។
3. កុំប្រើពាក្យអវិជ្ជមានក្នុងអំណះអំណាង នៅពេលសរសេរសំណួរខុសត្រូវ។ អំណះអំណាងដែល មានប្រើពាក្យអវិជ្ជមាន
4. កុំដាក់ធាតុច្រើន ដែលធាតុខ្លះពិត និង ធាតុខ្លះមិនពិតនៅក្នុងអំណះអំណាងតែមួយ។

**ឧទាហរណ៍ៈ**

ត/ខ សំឡេងធ្វើដំណើរតាមខ្យល់ តាមវត្ថុរាវ តាមវត្ថុរឹង និងតាមសុញ្ញកាស។

5. កុំប្រើអំណះអំណាងដែលជាមតិយោបល់មួយនៅក្នុងសំណួរត្រូវ / ខុស លើកលែងតែករណី ដែលបានកំណត់ថា ជាមតិរបស់អ្នកណា។

**ឧទាហរណ៍ៈ**

<u>**មិនល្អ**</u>

ត/ខ  សម័យអង្គរ ជាសម័យដ៏រុងរឿងបំផុតនៃប្រទេសកម្ពុជា។

<u>**ល្អ**</u>

ត/ខ ផ្អែកទៅតាមអ្នកប្រវត្តិសាស្ត្រជាច្រើន សម័យអង្គរជាសម័យដ៏រុងរឿងបំផុតនៃប្រទេសកម្ពុជា។

6. ជៀសវាងការយកលំនាំចម្លើយតាមលំដាប់ដដែលៗក្នុងសំណួរត្រូវ/ខុស បានន័យថា ត្រូវព្យាយាមផ្លាស់ប្តូរលំដាប់ចម្លើយត្រូវ/ខុស ឱ្យបានច្រើនបំផុត។
7. ប្រើចំណុចខុសឱ្យបានច្រើនជាងចំណុចត្រូវ ក្នុងការបង្កើតផ្នែកត្រូវ/ខុស។ ចំណុចនេះនឹងជួយសិស្សក្នុងការបង្កើនទម្លាប់ក្នុងការជជីកសួររកភាពត្រឹមត្រូវអ្វីដែលបានគេបានអាន។ សិស្សត្រូវដឹងថា អ្វីៗដែលគេបានបោះពុម្ព ពុំមែនសុទ្ធតែត្រឹមត្រូវពិតប្រាកដនោះទេ ៕

# VI.សំណួរចំណែកថ្នាក់

*A. ព័ត៌មានទូទៅ:*

- សំណួរចំណែកថ្នាក់គឺស្រដៀងគ្នានឹងសំណួរផ្គូផ្គង។
- សំណួរនេះមានគុណសម្បត្តិច្រើនលើការវាស់វែងបំណិនកម្រិតខ្ពស់ដូចជា បំណិនអនុវត្ត និងវិភាគ។

**ឧទាហរណ៍ទី១៖**

- **សេចក្តីណែនាំ៖** សំណួរ១ដល់៥គឺសួរអំពីភាវៈមានជីវិត និងភាវៈគ្មានជីវិត។ អ្នកត្រូវជ្រើសរើសឈ្មោះក្រុមដែលពិពណ៌នាងពីសំណួរទាំងនេះដោយដាក់អក្សរ "ក" ឬ "ខ" នៅក្នុងចន្លោះចំហរនៅខាងឆ្វេងសំណួរ។

| | |
|---|---|
| ___ ១. ថ្ម | ក. ភាវៈមានជីវិត |
| ___ ២. ទឹក | ខ. ភាវៈគ្មានជីវិត |
| ___ ៣. ស្មៅ | |
| ___ ៤. រថយន្ត | |
| ___ ៥. ទន្សាយ | |

**ឧទាហរណ៍ទី២៖**

**គំនិត៖ ប្រជាធិបតេយ្យគឺជាវិធីគ្រប់គ្រងល្អ។**

- **សេចក្តីណែនាំ៖** ចូរអានល្បះចំនួន៥ខាងក្រោម។ ល្បះខ្លះគាំទ្រគំនិតខាងលើ ល្បះខ្លះប្រឆាំងគំនិតខាងលើ និងល្បះខ្លះមិនពាក់ព័ន្ធ។ ចូរសរសេរអក្សរ "គ" (គាំទ្រ), "ប" (ប្រឆាំង), ឬ "មព" (មិនពាក់ព័ន្ធ)ខាងមុខល្បះខាងក្រោមទៅតាមស្ថានភាពរបស់វា។

___ ១. សេរីភាពជាចំណុចមួយដែលប្រជាជនចង់បាន។

___ ២. កុំទុកចិត្តមនុស្សជាមួយនឹងអំណាច។

___ ៣. ប្រទេសដែលរីកចម្រើនជាងគេនៅក្នុងលោកគឺប្រកាន់យកលទ្ធិប្រជាធិបតេយ្យ។

___ ៤. លទ្ធិកុម្មុយនីសជាវិធីគ្រប់គ្រងមិនល្អ

___ ៥. មនុស្សភាគច្រើនងាយនឹងចាញ់បោកមេដឹកនាំមិនល្អ។

# VII. សំណួរសំណេរ

## *A. ព័ត៌មានទូទៅ:*

សំណួរសំណេរជួនកាលហៅថា សំណួរ "ចម្លើយដោយសេរី" ។ សំណួរបែបនេះតម្រូវឱ្យសិស្សបង្កើតចម្លើយសំណេរជាទម្រង់កថាខណ្ឌ បានន័យថា វាមិនដូចសំណួរមិនលំអៀងនោះទេ។

សំណួរសំណេរ គឺជាទម្រង់ចាស់ជាងគេបំផុត ដែលគេប្រើក្នុងការប្រើតេស្តប្រឡង ហើយដែលនិយមប្រើជាច្រើនសតវត្សរ៍មកហើយ។

- ដោយហេតុថាសំណួរសំណេរប្រើពេលយូរក្នុងការឆ្លើយ ដូចនេះសំណួរបែបនេះជួយយើងក្នុងការវាយតម្លៃតែទំហំតូចនៃខ្លឹមសារដែលបានកំណត់ប៉ុណ្ណោះ។ សំណួរជ្រើសរើស 60 ល្អជាងសំណួរសំណេរចំនួន 4 ។
- ទោះបីថា សំណួរសំណេរជាទូទៅងាយស្រួលតែងជាងសំណួរមិនលំអៀង តែគ្រូគួរតែដឹងថា ការដាក់ពិន្ទុលើសំណួរសំណេរជាកិច្ចការលំអៀងណាស់។ គ្រូអាចធ្វើឱ្យប្លែកគ្នាជាសំខាន់ចំពោះការឱ្យរង្វាន់ លើពិន្ទុដែលគេឱ្យទៅលើចម្លើយសិស្សដូចគ្នា។ ចំពោះហេតុផលនេះគ្រូត្រូវតែប្រុងប្រយ័ត្ននៅពេលកែសំណួរសំណេរ។

## *B. ប្រភេទនៃសំណួរសំណេរ*

1. **សំណួរសំណេរសេរី** ( Extended Response Essay Question )

- សំណួរសំណេរសេរី គ្មានលក្ខខណ្ឌកំណត់ទៅលើសិស្សក្នុងការជ្រើសរើសព័ត៌មានដែលទាក់ទងទៅនឹងសំណួរ ការរៀបចំព័ត៌មាន និង គ្មានការវាយតម្លៃនៃគំនិត។ ការខ្វះរចនាសម្ព័ន្ធនេះ បង្ហាញពីការលំបាកក្នុងការដាក់ពិន្ទុ ពីព្រោះចម្លើយរបស់សិស្សពុំមានភាពស្រដៀងលើប្រវែង និង លើលក្ខណៈនៃសំណេរទេ។ ទោះយ៉ាងនេះក៏ដោយ ក៏ប្រភេទនៃសំណួរបែបនេះ អាចឱ្យគ្រូរកឃើញផងដែរ ថា តើសិស្សអនុវត្តបានល្អយ៉ាងណា ចំពោះកម្រិតសំយោគ និង ការវាយតម្លៃនៃការគិត។

  **ឧទាហរណ៍:** ចូរជ្រើសរើសអំណានរឿងមួយដែលអ្នកចូលចិត្តអានហើយពន្យល់ពីមូលហេតុ។

2. **សំណួរសំណេរមានលក្ខខណ្ឌកំណត់** ( Restricted Response Essay Question )

- ក្នុងសំណួរសំណេរបែបនេះ គោលការណ៍ណែនាំជាក់លាក់ ត្រូវបានផ្តល់ឱ្យសិស្ស ដើម្បីកំណត់លក្ខខណ្ឌទាំងខ្លឹមសារនិងទម្រង់នៃចម្លើយ។ រចនាសម្ព័ន្ធច្រើនបែបនេះ ធ្វើឱ្យងាយស្រួលក្នុងការដាក់ពិន្ទុ ប៉ុន្តែមិនផ្តល់នូវរង្វាស់នៃបំណិនរបស់សិស្សក្នុងការធ្វើសំយោគនិង

វាយតម្លៃព័ត៌មាននោះទេ។ប្រភេទសំណួរបែបនេះ ប្រសើរបំផុតសម្រាប់វាស់លទ្ធភាពនៃការសិក្សាតាមកម្រិតនៃការយល់ដឹង និងការអនុវត្តនៃការគិត។

**ឧទាហរណ៍:** ចូរកំណត់ស្តេចអង្គណានៅក្នុងសម័យអង្គរ ដែលគួរចាត់ទុកថា ជាស្តេចដ៏ល្បីល្បាញនៅក្នុងសម័យនោះ។ បញ្ជាក់ឱ្យបានច្បាស់លាស់ក្នុងការពិភាក្សា ស្នាដៃសម្រេចបានចំពោះសង្គម នយោបាយ និង វប្បធម៌។ រក្សាចម្លើយរបស់អ្នកត្រឹមមួយទំព័រកន្លះ ឬ តិចជាង។

- ក្នុងឧទាហរណ៍ខាងលើ យើងអាចឃើញថា សិស្សត្រូវបានសួរដោយផ្តោតទៅលើបីផ្នែកៈ ស្នាដៃសង្គម (**ឧទាហរណ៍:** ការសាងសង់សាលារៀន និង មន្ទីរពេទ្យ) ស្នាដៃនយោបាយ (**ឧទាហរណ៍:** ការពង្រីកទឹកដីអាណាចក្រកម្ពុជា) និង ស្នាដៃវប្បធម៌ (**ឧទាហរណ៍:** ការសាងសង់អាគារ និង វត្ត ឬ ប្រាសាទល្បីៗ) ។ មានន័យថា គេត្រូវឱ្យកំណត់ចម្លើយរបស់គេទៅលើផ្នែកទាំងនេះ។ ម៉្យាងទៀតគេបានកំណត់ប្រវែងឱ្យសិស្សសរសេរផងដែរ។ និយាយរួម ចម្លើយរបស់សិស្សត្រូវបាន "កំណត់លក្ខខណ្ឌ" 3 ឬ 4 ។ ដូច្នេះសំណួរនេះមានភាពប្លែកគ្នា បើប្រៀបធៀបទៅនឹងសំណួរទីមួយ ដែលគ្មានការកំណត់លក្ខខណ្ឌទៅលើចម្លើយរបស់សិស្ស។

### C. *សំណូមពរនៅពេលសរសេរសំណួរសំណេរ*

1. បញ្ជាក់ឱ្យបានច្បាស់ថា សំណួរសំណេររបស់អ្នកកំពុងធ្វើតេស្តការយល់ដឹងរបស់សិស្សតាមកម្រិតអនុវត្ត ឬ កម្រិតខ្ពស់ជាង។ បើសំណួររបស់អ្នកគ្រាន់តែសួររកព័ត៌មានតាមកម្រិតចងចាំទេនោះ គួរតែសរសេរសំណួរឡើងវិញដោយប្រើទម្រង់សំណួរមិនលំអៀង។
2. ចូរប្រើពាក្យ "ណែនាំ" ដែលសមរម្យទៅនឹងកម្រិត នៃការគិតដែលអ្នកចង់វាយតម្លៃ។ បញ្ជីពាក្យណែនាំដែលអាចប្រើបាន ផ្អែកទៅតាមកម្រិតនៃការគិត ដូចមានខាងក្រោមៈ
3. ចៀសវាងការប្រើពាក្យណែនាំមិនច្បាស់ ឬ ស្រពិចស្រពិលនៅក្នុងសំណួរដូចជា "ពិភាក្សា".
   **ឧទាហរណ៍:**
   ពិភាក្សាភាពខុសគ្នារវាងមនុស្សដែលរស់នៅតាមឆ្នេរសមុទ្រនិងមនុស្សដែលរស់នៅលើភ្នំ។
   (សំណួរមិនល្អ)

## ពាក្យណែនាំសម្រាប់សំនួរតែងសេចក្តី

ជណ្តើរនេះបង្ហាញពីបញ្ជីពាក្យណែនាំខ្លះនិងកម្រិតនៃការគិតដែលទាក់ទងនិងពាក្យនេះ។ ពេលខ្លះជំហានអាចជាន់លើគ្នា។ ការអនុវត្តត្រូវរួមបញ្ចូលការចងចាំហើយអាចត្រូវការ ការវិភាគសំយោគ និង ការវាយតម្លៃផងដែរ។ ពាក្យណែនាំខ្លះអាចផ្លាស់ប្តូរកម្រិតរបស់វាទៅតាមន័យនៃសំនួរ។
ឧទាហរណ៍:
កំនត់ភាពប្រហាក់ប្រហែលគ្នារវាងសត្វដែលគ្មានឆ្អឹង និង សត្វដែលមានឆ្អឹងខ្នង (វិភាគ)

- ការពារ
- បានធ្វើការសន្និដ្ឋានខ្លះ
- វិនិច្ឆ័យ
- វាយតម្លៃ
- បង្ហាញភាពសមហេតុផល
- .....ណាមួយដែលអ្នកចូលចិត្តបំផុត
- ហេតអ្វី

- ស្នើររកវិធីផ្សេង...
- ប្រឌិតឡើង...
- របៀបណាទៀតដែលអ្នកត្រូវ..
- កសាង...
- បង្កើត...
- ប្រៀបធៀប..

- តើទំនាក់ទំនងអ្វីដែលមាន...
- កំនត់នូវគំនិតចម្បង...
- វិភាគ...
- ពិនិត្យ...
- វែកញែក...
- ប្រៀបធៀប និង ធ្វើឱ្យឃើញភាពខុសគ្នា

- អនុវត្ត
- តើអ្វីនឹងកើតឡើងបើសិនជា...
- ពន្យល់របៀប__និងមានប្រតិកម្មទៅនឹង....
- បង្ហាញ...
- បកស្រាយ....
- បង្ហាញភស្តុតាង....

- ហេតុអ្វី.....
- ដូចម្តេច.....
- ថ្លែងពាក្យផ្ទាល់របស់អ្នក...
- បង្ហាញ ឬ បកស្រាយថា...
- បកស្រាយ...
- សង្ខេប
- ប្រាប់ឡើងវិញ..

- អ្វី.....
- នៅឯណា.....
- នៅពេលណា...
- អ្នកណា...
- ឱ្យអត្ថន័យ...
- ធ្វើគម្រោង
- ថ្លែង..
- ធ្វើបញ្ជី
- រៀបរាប់

ប្រៀបធៀបនឹងធ្វើឱ្យឃើញភាពខុសគ្នា រវាងមនុស្សដែលរស់នៅតាមឆ្នេរសមុទ្រ និង មនុស្សដែលរស់នៅលើភ្នំ។ (សំណួរល្អ)

4. ព្យាយាមផ្តល់ឱ្យសិស្សនូវព័ត៌មានឱ្យបានច្រើន ដើម្បីឱ្យគេអាចឆ្លើយនឹងសំណួរបាន។ ឧទាហរណ៍ៈ ត្រូវប្រាប់លក្ខណៈវិនិច្ឆ័យដែលប្រើក្នុងកំណែចម្លើយរបស់គេ។ លក្ខណៈវិនិច្ឆ័យបែបនេះអាចមានការរៀបចំគំនិត អក្ខរាវិរុទ្ធ វេយ្យាករណ៍ វណ្ណយុត្តិ ។ល។..
5. គ្រូគួរប្រាប់ផងដែរនូវពិន្ទុសរុបនៃសំណួរនីមួយៗ (ធ្វើយ៉ាងនេះសិស្សអាចលៃពេលវេលារបស់គេដោយមានប្រសិទ្ធភាព ) និងប្រវែងនៃចម្លើយដែលចង់បាន។
6. បញ្ជាក់ឱ្យច្បាស់ថា សិស្សទាំងអស់កំពុងឆ្លើយនឹងសំណួរដូចៗគ្នា។ ពេលខ្លះគ្រូចង់ឱ្យសិស្សជ្រើសរើសសំណួរដើម្បីឆ្លើយ។ ការអនុវត្តន៍បែបនេះគួរចៀសវាង ពីព្រោះទម្លាប់នេះបំផ្លាញលទ្ធភាពនៃការប្រៀបធៀបពិន្ទុរបស់សិស្សខុសៗគ្នា។ បើអាចឱ្យសិស្សជ្រើសរើសសំណួរខ្លះក្នុងចំណោមសំណួរទាំងអស់ គឺអាចឱ្យសិស្សទាំងអស់ឆ្លើយសំណួរចំបងដូចគ្នា ហើយទើបផ្តល់ការជ្រើសរើសខ្លះក្នុងចំណោមសំណួរ 3 ឬ 4 ដែលមិនសូវសំខាន់។
7. ត្រូវប្រាកដក្នុងចិត្តថា សំណួរទាំងអស់របស់អ្នក សិស្សអាចឆ្លើយបានទៅតាមរយៈពេលដែលអ្នកបានកំណត់ឱ្យគេ។ ជាញឹកញាប់គ្រូតែងតែដាក់សំណួរជាច្រើនឱ្យសិស្សឆ្លើយ ហើយគាត់កំណត់ពេលវេលាខ្លី ដែលជាហេតុធ្វើឱ្យសិស្សមិនអាចឆ្លើយទាន់។ សូមសាកល្បងនឹងសំណួរដែលបម្រុងដាក់ឱ្យសិស្សធ្វើដោយខ្លួនឯងសិន ហើយត្រួតពិនិត្យមើលរយៈពេលដែលគ្រូត្រូវឆ្លើយ។ អ្នកត្រូវថែម 5 ឬ 6 នាទីក្នុងសំណួរនីមួយៗ រួចបូករយៈពេលដែលគ្រូឆ្លើយ និងរយៈពេលបន្ថែមលើសំណួរទាំងអស់។ ធ្វើការប្រៀបធៀបរយៈពេលកំណត់ និង រយៈពេលតម្រូវការរបស់សិស្ស ដែលបានរកឃើញ បើសិនជារយៈពេលតម្រូវការរបស់សិស្ស វែងជាងរយៈពេលកំណត់ សូមបន្ថយសំណួរមួយចំនួនចេញវិញ។

## *D. សំណូមពរនៅពេលកែសំណួរសំណេរ*

- ការដាក់ពិន្ទុលើសំណួរសំណេរមានការលំបាកណាស់។ តាមការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា គ្រូម្នាក់ៗបានឱ្យពិន្ទុខុសៗគ្នាក្នុងការកែសំណួរសំណេរតែមួយ។ ម៉្យាងទៀតគ្រូតែម្នាក់ដែលកែសំណួរសំណេរតែមួយ តែកែច្រើនដង ពិន្ទុដែលគាត់បានឱ្យទៅលើសំណួរដដែលនោះក៏ខុសៗទៅតាមពេលវេលាផ្សេងៗគ្នាដែរ។ ក្នុងការសិក្សាមួយ គេឱ្យគ្រូ 100 នាក់ ដាក់ពិន្ទុលើកិច្ចការសំណេរមួយរបស់សិស្សម្នាក់ដែលរៀនថ្នាក់ទី 12។ បន្ទាប់មកគេឱ្យរៀបពិន្ទុទាំងនោះរៀងតាមលំដាប់ ហើយឱ្យវិនិច្ឆ័យថា តើសិស្សនោះរៀនថ្នាក់ទីប៉ុន្មាន។ បណ្តាពិន្ទុដែលគ្រូទាំងនោះបានឱ្យទៅលើសំណួរតែសេចក្តីនោះមានពី 60 % ទៅ 98 % ហើយចំពោះថ្នាក់ដែលបានប៉ាន់ស្មានមានពីថ្នាក់ទី 5 ទៅដល់ថ្នាក់ឆ្នាំទី 2 នៃសាកលវិទ្យាល័យ។ ករណីដាក់ស្តែងបែបនេះ គ្រូត្រូវតែមានការប្រុងប្រយ័ត្នបំផុតក្នុងការដាក់ពិន្ទុសំណួរសំណេរ។

- ខាងក្រោមនេះជាគោលការណ៍ណែនាំខ្លះដែលមានប្រយោជន៍ ដើម្បីប្រើក្នុងការដាក់ពិន្ទុសំណួរសំណេរ។ យើងត្រូវចាំថា វាតែងតែមានភាពលំអៀងខ្លះក្នុងការដាក់ពិន្ទុរបស់យើង។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ចំណុចសំខាន់ដែលត្រូវចងចាំ គឺចង់ឱ្យភាពលំអៀងនោះមានកម្រិតតិចតួចបំផុត។

1. ត្រូវរៀបចំ "ចម្លើយគម្រូ" មួយជាមុនក្នុងការកែកិច្ចការសិស្ស។ ពិនិត្យចម្លើយគម្រូនេះហើយផ្ទៀងវាទៅនឹងសន្លឹកកិច្ចការខ្លះ (2 ឬ 3) មុននឹងចាប់ផ្ដើមកែកិច្ចការយកមែនទែន។ អ្នកអាចត្រួតពិនិត្យឡើងវិញនូវលក្ខណៈវិនិច្ឆ័យរបស់អ្នក បើអ្នកយល់ឃើញថា សេចក្ដីរំពឹងរបស់អ្នកខ្ពស់ហួសពេក។ នៅពេលដែលអ្នកបានបញ្ចប់ ការកែសម្រួលលក្ខណៈវិនិច្ឆ័យរបស់អ្នកហើយនោះ គឺអ្នកបានត្រៀមលក្ខណៈក្នុងការចាប់ផ្ដើមដាក់ពិន្ទុហើយ។
2. ក្នុងការសរសេរ "ចម្លើយគម្រូ" របស់អ្នក ត្រូវព្យាយាមរកឱ្យឃើញនូវលក្ខណៈវិនិច្ឆ័យដាក់លាក់នៃការដាក់ពិន្ទុ ដូចជាវិធីប្រើវណ្ណយុត្តិ អក្ខរាវិរុទ្ធ ការរៀបចំ និង ចំនួនពិន្ទុដែលសមរម្យទៅនឹងលក្ខណៈវិនិច្ឆ័យនីមួយៗ។
   ឧទាហរណ៍ៈ ក្នុងការដាក់ពិន្ទុលើសំណេរខាងភាសា គ្រូអាចបែងចែកជាងអតិបរមា 5 ពិន្ទុសម្រាប់ការរៀបចំ 3 ពិន្ទុសម្រាប់វេយ្យាករណ៍ និង 2 ពិន្ទុសម្រាប់អក្ខរាវិរុទ្ធ និងការប្រើវណ្ណយុត្តិ។
3. យូរៗម្ដង ត្រូវធ្វើនិទស្សន៍ឡើងវិញនូវ "ស្ដង់ដារជាមូលដ្ឋាន" នៃការដាក់ពិន្ទុ។ ការធ្វើទៅតាមទម្លាប់ អាចចោទ ជាបញ្ហាក្នុងការដាក់ពិន្ទុសំណួរសំណេរ។ នេះមានន័យថា ពេលខ្លះស្ដង់ដាររបស់យើង ប្រែប្រួលទៅតាមសន្លឹកកិច្ចការក្រោយ ដែលគ្រូទើបនឹងដាក់ពិន្ទុ។ ដូច្នេះយូរៗម្ដងគ្រូត្រូវមើលកិច្ចការ 2 ឬ 3 ដែលបានដាក់ពិន្ទុពីដំបូង។ ធ្វើបែបនេះ គឺបានរក្សាទុកនូវស្ដង់ដារនៃការដាក់ពិន្ទុតែមួយ តាំងពីដើមរហូតដល់ទីបញ្ចប់នៃការវាយតម្លៃ។
4. ត្រូវដាក់ពិន្ទុសំណួរតែមួយលើគ្រប់សន្លឹកកិច្ចការទាំងអស់ ទើបចាប់ផ្ដើមដាក់ពិន្ទុ សំណួរមួយទៀតហើយធ្វើរបៀបនេះរហូតដល់សំណួរចុងក្រោយ។ ការធ្វើបែបនេះ ល្អជាងការដាក់ពិន្ទុគ្រប់សំណួរទាំងអស់លើសន្លឹកកិច្ចការតែមួយចប់ហើយ ទើបចាប់ផ្ដើមដាក់ពិន្ទុលើសន្លឹកកិច្ចការមួយទៀត។ វាធ្វើឱ្យយើងប្រាកដក្នុងចិត្តថា យើងបានរក្សាស្ដង់ដារតែមួយក្នុងពេលពិន្ទុ វាក៏ជួយយើងក្នុងការបង្កើនការចាំច្បាស់អំពីលក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុដែលយើងត្រូវប្រើទៅលើសំណួរនោះផងដែរ។
5. ត្រូវដាក់ពិន្ទុលើសន្លឹកកិច្ចការ ដោយមិនចាំបាច់ស្គាល់ឈ្មោះសិស្សទេ។ ធ្វើបែបនេះនឹងជួយកាត់បន្ថយ ភាពលំអៀងទៅលើសិស្សខ្លះដែលគ្រូស្គាល់ថា ជាសិស្សល្អ (ឬ សិស្សមិនល្អ)។
6. ត្រូវព្យាយាមញែកមេកានិច (Mechanics) ក្នុងការសរសេរ ឱ្យដាច់ដោយឡែកពីខ្លឹមសារដែលត្រូវវាយតម្លៃ។ ចំណុចនេះសំខាន់ណាស់ក្នុងការដាក់ពិន្ទុលើមុខវិជ្ជាផ្សេងៗ ក្រៅពីភាសាខ្មែរ គ្រូតែងតែឱ្យពិន្ទុខ្ពស់ទៅលើកិច្ចការណា ដែលសិស្សសរសេរបានល្អលើរចនាបទ ទោះបីជាកិច្ចការដែលគេសរសេរនោះមានខ្លឹមសារមិនសូវល្អ ឬ មិនទាក់ទងគ្នាក៏ដោយ។

នេះជាគោលការណ៍ណែនាំសំខាន់បំផុតមួយ ក្នុងបណ្ដាគោលការណ៍សំខាន់ដទៃទៀត ដែលគ្រូត្រូវប្រកាន់ឱ្យបានខ្ជាប់។

7. គ្រូព្យាយាមដាក់ពិន្ទុ សំណួរណាមួយលើសន្លឹកកិច្ចការទាំងអស់ ដោយគ្មានការបង្អាក់ឬរំខានកណ្ដាលទី។ ការប្រែប្រួលអារម្មណ៍ ការប្រែប្រួលកម្រិតថាមពល ល។ នៅពេលដែលកិច្ចការពីពេលមួយទៅពេលមួយទៀតអាចប៉ះពាល់ដល់ការសម្រេចចិត្តក្នុងការដាក់ពិន្ទុ បើអ្នកហត់នឿយ ឬ អ្នកមានអារម្មណ៍មិនល្អ សូមកុំដាក់ពិន្ទុសំណួរសំណេរឱ្យសោះ។
8. រៀបចម្ការដាក់ពិន្ទុផ្សេងគ្នា ចំពោះសំណួរនីមួយៗ។ នោះមានន័យថា គ្រូម្នាក់ៗក្នុងចំនោមគ្រូពីរនាក់ ត្រូវដាក់ពិន្ទុសំណួរនីមួយៗ រៀងៗខ្លួន រួចទើបប្រៀបធៀបពិន្ទុនោះ។ គ្រូគួរធ្វើតាមរបៀបនេះ បើសិនវាជាតេស្តសម្រាប់ធ្វើការប្រឡងដ៏សំខាន់ដូចជា ការឡើងថ្នាក់ / ការត្រួតថ្នាក់ជាដើម។ បើយើងប្រៀបធៀបពិន្ទុរវាងអ្នកកែទាំងពីរ ឃើញថាមានការខុសគ្នាខ្លាំងពេក យើងត្រូវពិភាក្សានិងដោះស្រាយភាពខុសគ្នានោះ។ ប៉ុន្តែបើពិន្ទុនោះមានការខុសគ្នាបន្តិចបន្តួច ត្រូវរកមធ្យមភាគវា ហើយវាជាពិន្ទុចុងក្រោយបង្អស់។៚